# អាខ្វាក់ អាខ្វិន



កាលពីព្រេងនាយ មានបុរសពីរនាក់ ម្នាក់ខ្វាក់ភ្នែកទាំងសងខាង និងម្នាក់ទៀតខ្វិនជើងទាំងពីរដើរមិនរួច នៅជាអ្នកបម្រើគេដូចគ្នា។ ពួកគេមានចៅហ្វាយផ្សេងពីគ្នា ចៅកែសុទ្ធតែជាមនុស្សចិត្តអាក្រក់ ប្រើពួកគេឱ្យធ្វើការគ្មានត្រាប្រណី អស់អ្នកស្រុកហៅគេថា **អាខ្វាក់ អាខ្វិន** ពួកគេយកគ្នាជាមិត្តសម្លាញ់។ ថ្ងៃមួយ **អាខ្វិន** និយាយថា "ហ៊ឺ! យើងពិបាក និង នឿយហត់ខ្លាំងណាស់ ទ្រាំរស់នៅជាខ្ញុំគេតទៅទៀតមិនបានទេ យើងគួរតែលួចរត់ចេញពីទីនេះ"។ **អាខ្វាក់** សួរ **អាខ្វិន** ថា "ឥឡូវយើងធ្វើយ៉ាងដូចម្តេចទៅ?" **អាខ្វិន** ឆ្លើយថា "អញឃើញទូកមួយនៅមាត់កំពង់ យើងជិះទូកនោះចេញនៅយប់នេះទៅ"។



បន្ទាប់ពីពួកគេគិតត្រូវរ៉ូវគ្នាហើយ ក៏ទ្រាំដល់ពេលរាត្រីស្ងាត់ ទើបនាំគ្នាចុះទូកទាំងពីរនាក់។ ប៉ុន្តែ **អាខ្វាក់ អាខ្វិន** ជាមនុស្សមិនចេះអុំទូកឡើយ ពួកគេអង្គុយលើក្បាលទូកម្ខាងម្នាក់ទល់មុខគ្នា តាំងចិត្តខំអុំទូករៀងខ្លួន។ ដោយសារពេលយប់ងងឹតមើលអ្វីមិនឃើញនោះ ពួកគេគិតតែពីអុំទូក ស្មានថាទូកកំពុងលឿនទៅមុខ ផ្ទុយទៅវិញទូកវិលនៅនឹងកន្លែង។ លុះពេលពាក់កណ្ដាលអាធ្រាត្រ ក៏ឮសម្លេងសត្វអកយំ **អាខ្វាក់** និយាយថា "យើងប្រឹងឡើងដល់កន្លែងអន្លង់អកហើយ"។ ពួកគេទាំងពីរនាក់ក៏ចេះតែអុំៗរហូតដល់មាន់រងាវ **អាខ្វិន** និយាយថា "យើងជិតដល់ស្រុកគេហើយ ខំប្រឹងអុំឡើងក្រែងមានគេមកតាម"។ **អាខ្វាក់ អាខ្វិន** ក៏ប្រឹងអុំទូកលុះត្រាតែមាន់រងាវកុះ ឮសម្លេងសត្វតាវ៉ៅយំផ្ទៃមេឃភ្លឺព្រាលៗពីទិសខាងកើត។ **អាខ្វិន** និយាយប្រាប់ **អាខ្វាក់** ថា "យីអើ! ដូចជាកំពង់ក្បែរផ្ទះយើង?"

លុះភ្លឺបន្តិច ម្ចាស់ចុះមកដងទឹកឃើញ **អាខ្វាក់ អាខ្វិន** អង្គុយអុំទូក ទល់មុខគ្នា ក៏នាំពួកគេត្រឡប់ទៅផ្ទះវិញ ព្រោះដឹងថា ពួកគេច្បាស់ ជាចង់រត់ចេញពីទីនេះហើយ។ បន្ទាប់មក **អាខ្វាក់ អាខ្វិន** ក៏រស់នៅ

លុះនៅយូរបន្តិចទៅ **អាខ្វាក់ អាខ្វិន** ក៏បបួលគ្នារត់ម្ដងទៀត **អាខ្វាក់** និយាយថា "ម្ដងនេះ យើងកុំទៅតាមផ្លូវទឹក យើងធ្វើដំណើរតាមផ្លូវគោកម្ដង"។ **អាខ្វិន** ឆ្លើយថា "តើធ្វើយ៉ាងម៉េចទៅបើឯងខ្វាក់ អញខ្វិន រត់ទៅឯណាម្ដេចនឹងរួចទៅ?" **អាខ្វាក់** ឆ្លើយឡើងថា "ឯងកុំព្រួយ! ឯងជិះកអញ ហើយឯងប្រាប់ផ្លូវដល់អញទៅ វាជាការស្រេច"។ លុះដល់ពេលយប់ស្ងាត់ **អាខ្វាក់** អង្គុយចុះឱ្យ **អាខ្វិន** ឡើងជិះលើស្មា បង្ហាញផ្លូវចេញទៅទាំងយប់។







បីថ្ងៃក្រោយមក ពួកគេក៏បានទៅដល់ស្រុកមួយ ស្រុកនោះមានខ្លាកាចសាហាវណាស់។ ដល់ពេលព្រលប់ អ្នកស្រុកហាមប្រាម កូនចៅមិនឱ្យដើររហេតរហូតឡើយ ព្រោះខ្លាចខ្លាស៊ី។ **អាខ្វាក់ អាខ្វិន** ទៅដល់ស្រុកនោះ ជួនជាពេលព្រលប់បន្តិច **អាខ្វិន** និយាយថា "ឥឡូវយើងមកដល់ស្រុកគេហើយ យើងត្រូវតែធ្វើស្រែ"។ "ធ្វើយ៉ាងដូចម្តេចទៅ តើយើងបាននង្គ័ល រនាស់ គោក្របីមកពីណា?" **អាខ្វាក់** បន្ថែម។ **អាខ្វិន** ប្រើ **អាខ្វាក់** ដើរចូលទៅក្នុងភូមិ អ្នកស្រុកបានប្រាប់ពួកគេថា "នែក្មួយទាំងពីរ ស្រុកនេះមានខ្លាកាចសាហាវណាស់"។ **អាខ្វាក់** ឆ្លើយឡើងថា "ឃ្លេមិនខ្លាច ទៅខ្លាចអីអាខ្លានោះ"។ ជួនជាខ្លាកំពុងចាំលបខាំមនុស្សក្បែរផ្ទះ វាឮ **អាខ្វាក់** និយាយដូច្នេះគិតថា "ពីដើមគេខ្លាចតែអញ ឥឡូវមានឃ្លេផ្សេង គេខ្លាចជាងអញទៅទៀត អញមិនដែលឃើញ មិនដែលឮទាល់តែសោះ បើដូច្នេះ អញចាំលបមើលឱ្យឃើញច្បាស់ប្រាកដសិន"។

**អាខ្វិន** ឃើញក្រោលគោគេ ប្រាប់ **អាខ្វាក់** ថា "ឯងទៅលួចគោគេទៅ អញចាំមើលផ្លូវខាងក្រៅរបង"។ **អាខ្វាក់** ដាក់ **អាខ្វិន** ចុះ ហើយដើរស្ទាបៗចូលទៅក៏ជួបនឹងខ្លា។ ខ្លាឃើញ **អាខ្វាក់** ស្មានថាជាឃ្លេ ក៏ខ្លាចមិនហ៊ានកំរើកខ្លួន។ **អាខ្វាក់** ស្ទាបអស់ទាំងប្រាណគិតថាជាគោ ស្ទាបទៅលើក្បាលខ្លាមិនមានស្នែងអរណាស់និយាយថា "ហ្អា! គោនេះស្នែងនប់ធាត់ល្អណាស់ អញទុកជាអានប់កូនក្រោល" **អាខ្វាក់** ក៏ចាប់ទាញខ្លាដឹកយកមកខ្លុះ។



ឯខ្លាគិតស្មានថាជាឃ្លេ ក៏ចេះតែបណ្ដោយខ្លួនទៅតាម **អាខ្វាក់** ។ លុះដឹកមកដល់ក្រោមរបង **អាខ្វាក់** ប្រាប់ **អាខ្វិន** យកកន្ត្រះខ្លុះអានប់កូនក្រោល។ **អាខ្វិន** ឃើញហើយប្រាប់ទៅ **អាខ្វាក់** ថា "**អាខ្វាក់** ខ្លាទេ" **អាខ្វាក់** ឆ្លើយថា "បើឯងខ្លាច ឯងហុចកន្ត្រះឱ្យអញមក អញនឹងចាក់ច្រមុះខ្លុះយកទៅភ្ជួរស្រែ"។ **អាខ្វិន** ហុចកន្ត្រះឱ្យ **អាខ្វាក់ៗ** បានកន្ត្រះហើយ ក៏ចាក់ច្រមុះខ្លាភ្លាម។ ខ្លាឈឺច្រមុះទ្រាំពុំបានក៏ស្ទុះច្រឡោតស្រែកព្រួសូរតែរ៉ូមៗ ហើយរត់ចូលព្រៃបាត់ទៅ។ **អាខ្វិន** ខ្លាចស្ទើរនឹងស្លាប់ ប៉ុន្តែ **អាខ្វាក់** មិនព្រមចេះតែទន្ទេញថា "ស្ដាយអានប់កូនក្រោលអញធាត់ល្អណាស់..."។



ពួកគេក៏ខំដើរទៅមុខទៀត លុះដល់វាលស្រែបានឃើញខ្ទមមួយមានទាំងរនាស់ហើយឃើញអណ្ដើកមួយ។ **អាខ្វិន** ឃើញហើយនិយាយប្រាប់ **អាខ្វាក់** ថា "អ៊ើយ **អាខ្វាក់** មានខ្ទមមួយនៅវាលស្រែ មានខ្សែពួរ និង ចង្អេរផង"។ **អាខ្វាក់** ប្រាប់ថា "ចេះតែយកឱ្យអស់ទៅ" **អាខ្វិន** ប្រកែកថា "យកធ្វើអីធ្ងន់ឥតអំពើ"។ **អាខ្វាក់** ឆ្លើយថា "ធ្ងន់អីឯង ធ្ងន់តែអញទេ ចេះតែយកទៅ"។ **អាខ្វិន** ប្រមូលយកគ្មានសល់ ព្រមទាំងបាយមួយឆ្នាំងទៀតផង។



**អាខ្វាក់** ជាមនុស្សមានសុខភាពរឹងមាំ កំលាំងក៏ខ្លាំង ដើរតាំងពីយប់រហូតដល់ភ្លឺបានជួបមនុស្សម្នាក់កំពុងយកឃ្មុំ។ **អាខ្វិន** ឃើញប្រាប់ **អាខ្វាក់** ថា "នែវើយ មានគេកំពុងយកឃ្មុំ"។ **អាខ្វាក់** ឮហើយ ស្រែកទៅអ្នកយកឃ្មុំថា "វើយចែកឃ្មុំគ្នាស៊ី" អ្នកយកឃ្មុំឆ្លើយថា "គ្នាស៊ីតែទឹកទេ ទុកសាច់ឱ្យឯង" ហើយអ្នកយកឃ្មុំហុចបំពង់ចុកឆ្អកជិតហុចឱ្យ **អាខ្វាក់** ។



ក្រោយមក **អាខ្វាក់ អាខ្វិន** ក៏ស្រាប់តែឃ្លានបាយ **អាខ្វាក់** និយាយថា "យើងស៊ីបាយសិន ឱ្យមានកំលាំងសឹមទៅមុខទៀត"។ **អាខ្វាក់** ដាក់ **អាខ្វិន** ចុះ យកបំពង់ឫស្សីដែលអ្នកយកឃ្នុំឱ្យនោះ ដោយស្មានថា



ជាសាច់ឃ្មុំ ក៏ទាញឆ្នុកចេញធុំក្លិនស្អុយលាមក **អាខ្វាក់** និយាយថា "កន្លែងនេះស្អុយណាស់ យើងទៅរកកន្លែងផ្សេងប្រសើរជាង"។ **អាខ្វាក់** ចុកបំពង់ជិតវិញ ហើយធ្វើដំណើរទៅមុខទៀត។ យូរបន្តិច **អាខ្វាក់** និយាយថា "ខ្ញុំឃ្លានបាយអស់កំលាំងកាន់តែខ្លាំងណាស់ទៅហើយ រកកន្លែងឈប់ស៊ីបាយសិន"។ **អាខ្វិន** ក៏មើលឃើញដើមឈើមានម្លប់ល្អ ហើយមានត្រពាំងនៅក្បែរនោះទៀត។ បន្ទាប់មក **អាខ្វាក់** ក៏ដកឆ្នុកបំពង់ធុំក្លិនស្អុយដដែល **អាខ្វាក់** លូកដៃចូលបំពង់ប៉ះសុទ្ធតែលាមកក៏លាន់មាត់ថា "នែវ៉ើយ **អាខ្វិន** អាដែងយកឃ្មុំឱ្យយើងនោះវាបញ្ឆោតយើងទេ វាជុះអាចម៍ដាក់ក្នុងបំពង់ចុកមាត់ ហើយយកមកឱ្យយើង"។ **អាខ្វាក់** ខឹងណាស់ លាងដៃរួចហើយនាំគ្នាស៊ីបាយមានកំលាំងធ្វើដំណើរទៅរកអ្នកយកឃ្មុំបម្រុងនឹងសងសឹក។